# ការទស្សនាព្រះវិហារបរិសុទ្ធ

*ស្វាគមន៍មកកាន់ព្រះវិហារបរិសុទ្ធ !*

នៅក្នុងព្រះវិហារបរិសុទ្ធ យើងអាចរៀនអំពីផែនការនៃសេចក្ដីសង្គ្រោះ ហើយធ្វើសេចក្ដីសញ្ញាជាមួយព្រះវរបិតាសួគ៌ ។ មានបន្ទប់ដ៏ស្រស់ស្អាតជាច្រើនដែលយើងអាចមានអារម្មណ៍នៃសេចក្ដីសុខសាន្តពីព្រះវិញ្ញាណបរិសុទ្ធ ។



*ព្រះវិហារបរិសុទ្ធ ហេលស៊ីនគី ហ្វាំងឡង់*

អាងជ្រមុជទឹក គឺជាកន្លែងដែលអ្នកអាចធ្វើបុណ្យជ្រមុជទឹកសម្រាប់មរណជន ។ រូបសំណាកគោដប់ពីរក្បាលនៅជុំវិញអាងជ្រមុជទឹកតំណាងឲ្យកុលសម្ព័ន្ធទាំងដប់ពីរនៃអ៊ីស្រាអែល ។

បន្ទប់កូនក្រមុំ គឺជាកន្លែងដែលស្ត្រីរៀបចំខ្លួនពីមុនពេលផ្សារភ្ជាប់ ។



*ព្រះវិហារបរិសុទ្ធ អៃដាហូ ហ្វល រដ្ឋអៃដាហូ*



*ព្រះវិហារបរិសុទ្ធ អ៊ីដាណេតា ហ្វីលីពីន*

បន្ទប់ផ្សារភ្ជាប់ គឺជាកន្លែងដែលគូស្វាមីភរិយា និងក្រុមគ្រួសារត្រូវបានផ្សារភ្ជាប់ជាមួយគ្នាសម្រាប់ជីវិតនេះ និងជីវិតដ៏អស់កល្បជានិច្ច ។



*ព្រះវិហារបរិសុទ្ធ ហ្គាតេម៉ាឡា កូបាន*

បន្ទប់ផ្តល់ការណែនាំ គឺជាកន្លែងដែលអ្នករៀនអំពីផែនការនៃសេចក្ដីសង្គ្រោះនិងធ្វើសេចក្ដីសញ្ញាពិសិដ្ឋជាមួយព្រះវរបិតាសួគ៌។

បន្ទប់សេឡេស្ទាល ជួយយើងគិតដល់ថាតើការរស់នៅជាមួយព្រះវរបិតាសួគ៌ម្តងទៀតនឹងមានលក្ខណៈបែបណា ។ វាជាកន្លែងដើម្បីធ្វើការអធិស្ឋាន ពិចារណា និងអានព្រះគម្ពីរ ។



*ព្រះវិហារបរិសុទ្ធ អូគីណាវ៉ា ជប៉ុន*

## បញ្ជីត្រួតពិនិត្យសម្រាប់ព្រះវិហារបរិសុទ្ធ

តើប្អូនៗអាចរកឃើញវត្ថុទាំងនេះនៅក្នុងព្រះវិហារបរិសុទ្ធបានឬទេ ?

- ☐ អំពូលត្រីស្ទាល់
- ☐ កញ្ចក់
- ☐ ផ្កាមួយចូ
- ☐ រូបសំណាកគោនៅអាងជ្រមុជទឹក
- ☐ ចម្លាក់ជាកញ្ចក់